00803422

002/19-09-2007-ECCC/TC
E1/62

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 27 / 04 / 2012
ម៉ោង (Time/Heure) : 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

**សាធារណៈ**

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃអង្គារ៍ ទី ១០ ខែ មេសា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ៥០

រៀបចំដោយៈ សែ កុលវុឌ្ឍី និង **Roger PHILLIPS**

---

| **កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ** |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោក ឌុច ផារី, លោក Roger PHILLIPS, |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, លោក William SMITH, លោក ពេជ្រ សម្បត្តិ |
| ជនជាប់ចោទ៖ អៀង សារី, នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Michiel PESTMAN, លោក Jasper PAUW |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS |

| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Elisabeth SIMONNEAU-FORT, លោក Barnabé NEKUIE, លោកស្រី ជេត វណ្ណលី, លោកស្រី Lyma NGUYEN, លោក ឡៅ ជុនធី, លោកស្រី Marie GUIRAUD, លោកស្រី ទី ស្រីនណា, លោក ហុង គីមសួន |
| សាក្សី៖ កាំង ហ្កេកអ៊ាវ ហៅ ឌុច (TCW-281) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ កញ្ញា Alexandra PRASSOLOFF |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃអង្គារ៍ ទី១០ ខែមេសា ឆ្នាំ២០១២ | ចាប់ផ្តើមម៉ោង៖ ៩.០០ | បញ្ចប់ម៉ោង៖ ១៦.១៥ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖១០.៤០ | បញ្ចប់ម៉ោង៖ ១១.០០ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.១០ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០០ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៥ ម៉ោង និង ១៥ នាទី |

| **កិច្ចដំណើរការនីតិវិធី៖** | | | |
|---|---|---|---|
| **ប្រភេទបញ្ហា** | **លើកឡើងដោយ** | **ម៉ោងចាប់ផ្តើម** | **ម៉ោងបញ្ចប់** |
| ការតាំងសំណួរទៅសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច | មេធាវីការពារក្តី ខៀវ សំផន<br>មេធាវីការពារក្តី នួន ជា | ៩.០០<br>១៥.១០ | ១៥.១០<br>១៦.០០ |
| ការបញ្ជាក់ទាក់ទងនឹងលក្ខណៈនៃការតាំងសំណួរ | អង្គជំនុំជម្រះ | ១០.១៥ | ១០.២៥ |
| សំណើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ | មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី នួន ជា | ១០.៣៥<br>១២.០៥ | ១០.៣៥<br>១២.០៥ |
| សំណើសុំទាក់ទងនឹងអាកប្បកិរិយារបស់ភាគីនៅក្នុងបន្ទប់សវនាការ | សហព្រះរាជអាជ្ញា | ១១.០៥ | ១១.០៥ |
| ការបញ្ជាក់អំពីសំណួរទៅសាក្សីដោយអង្គជំនុំជម្រះ | អង្គជំនុំជម្រះ | ១១.០៥ | ១១.១០ |

| | | | |
|---|---|---|---|
| ការសួរបញ្ជាក់ថាតើជនជាប់ចោទទាំងបីមានបំណងក្នុងការតទល់ជាមួយសាក្សី កាំង ហ្កេកអ៊ាវ ដែរឬទេ | អង្គជំនុំជម្រះ | ១៦.០០ | ១៦.១០ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការតាំងសំណួរទៅសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច**

មេធាវីការពារក្តី ខៀវ សំផន និងបន្ទាប់មកមេធាវីការពារក្តី អៀង សារី បានតាំងសំណួរទៅសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច។

**ការបញ្ជាក់ជាក់ទងនឹងលក្ខណៈនៃការ តាំងសំណួរ**

អង្គជំនុំជម្រះបានណែនាំទៅមេធាវីការពារក្តីឱ្យធ្វើការតាំងសំណួរឱ្យបានជាក់ច្បាស់ ហើយខ្លីដែលអាចឱ្យសាក្សីងាយយល់ និងអាចឆ្លើយនឹងសំណួរបាន។

**សំណើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ**

ជនជាប់ចោទ អៀង សារី និង នួន ជា តាមរយៈមេធាវីរបស់ពួកគេ បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ តែសុំចូលរួមសវនាការពីបន្ទប់រង់ចាំតាមរយៈប្រព័ន្ធសោតទស្សន៍។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំនេះ។

**សំណើរបស់សហព្រះរាជអាជ្ញាចំពោះអាកប្បកិរិយារបស់ភាគី**

សហព្រះរាជអាជ្ញាបានស្នើសុំឱ្យអង្គជំនុំជម្រះរំលឹកទៅភាគីឱ្យគោរពនូវវិធាន ២២.៤ ដែលបានចែងថាមេធាវីត្រូវមានកាតព្វកិច្ចក្នុងការលើកកម្ពស់យុត្តិធម៌ និងដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធិភាព និងត្រឹមត្រូវ។

**ការបញ្ជាក់អំពីសំណួរទៅសាក្សីដោយអង្គជំនុំជម្រះ**

អង្គជំនុំជម្រះបានសួរបញ្ជាក់ទៅសាក្សីកាំង ហ្កេកអ៊ាវ ហៅឌុច អំពីសំណួរដែលបានចោទសួរដោយមេធាវីការពារក្តី ខៀវ សំផន។

**ការសួរបញ្ជាក់ថាតើជនជាប់ចោទទាំងបីរូប មានបំណងធ្វើការតទល់ជាមួយសាក្សីកាំង ហ្កេកអ៊ាវ ដែរឬទេ**

អង្គជំនុំជម្រះបានសួរបញ្ជាក់ទៅមេធាវីការពារក្តីទាំងអស់ថា

តើកូនក្តីរបស់ពួកគេមានបំណងក្នុងការតទល់ជាមួយនឹងសាក្សី កាំង ហ្កេកអ៊ាវ ដែរឬទេ។ មេធាវីការពារក្តី នួន ជា បានបញ្ជាក់ថា ជនជាប់ចោទ នួន ជា ស្នើសុំធ្វើសេចក្តីថ្លែងការរបស់គាត់ដើម្បីឆ្លើយតបទៅនឹងសក្ខីកម្មរបស់សាក្សីរូបនេះ។ មេធាវីការពារក្តី អៀង សារី បានបញ្ជាក់ថា ជនជាប់ចោទ អៀង សារី នៅតែរក្សាជំហរក្នុងការមិនឆ្លើយតប ឬក៏តាំងសំណួរទៅសាក្សីនោះទេ។ មេធាវីការពារក្តី ខៀវ សំផន បានបញ្ជាក់ថា ជនជាប់ចោទ ខៀវ សំផន មិនតាំងសំណួរទៅសាក្សីរូបនេះទេ។ មេធាវីការពារក្តី នួន ជា បានបញ្ជាក់ថា ពួកគេនឹងធ្វើសេចក្តីថ្លែងការជំទាស់ចំពោះនីតិវិធីដែលបានសម្រេច ដោយអង្គជំនុំជម្រះ។ អង្គជំនុំជម្រះបានសម្រេច ឲ្យក្រុមមេធាវីការពារក្តី នួន ជា ដាក់នូវសេចក្តីថ្លែងការ ជាលាយលក្ខណ៍អក្សរចំពោះសំណើសុំនេះ ដោយឡែកជនជាប់ចោទ នួន ជា អង្គជំនុំជម្រះផ្តល់ឱកាសឲ្យគាត់ធ្វើសេចក្តីថ្លែងការណ៍ និងបន្ទាប់មកនឹងត្រូវសួរសំណួរដោយភាគី។

## <u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣)</u>

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/452 | D86/4 | 00146549-00146561<br>00147563-00147573<br>00147926-00147935 | កំណត់ហេតុនៃការសួរចម្លើយ ឌុច ចុះថ្ងៃទី ២៣ ៨ ២០០៧<br>Written Record of Interview of Duch by CIJ on 23-08-2007<br>Procès verbal d'interrogatoire de Duch par CJI le 23-08-2007 | P | 00146551 | | 00147929 |
| E3/107 | D89 | 00197967-00197977<br>00198217-00198225<br>00197978-00197986 | [លិខិតបញ្ជាក់ការជំនួសឯកសារ] កំណត់ហេតុនៃការសួរចម្លើយ ឌុច ចុះថ្ងៃទី ២៤ មិថុនា ២០០៨<br>[Surrogate Sheet] Written Record of Interview of Duch by CIJ on 24-06-2008<br>[Feuille remplacée] Procès verbal d'interrogatoire de Duch par CJI le 24-06-2008 | P | 00197973 | 00198222 | 00197983 |
| E3/355 | D117 | 00239830-00239840<br>00242872-00242882<br>00239820-00239829 | កំណត់ហេតុនៃការសួរចម្លើយ ឌុច ថ្ងៃទី ១៩ វិច្ឆិកា ២០០៨<br>Written Record of Interview of Duch by CIJ on 19-11-2008<br>Procès verbal d'interrogatoire de Duch par CJI le 19-11-2008 | P | 00239833 | 00242875 | 00239823 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/347 | 20.19 | 00160879-00160884, 00160889-00160920, 00002494-00002557 00160885-00160888, 00002494-00002557, 00184996-00185058 00160889-00160920, 00160921-00160974 | បទសម្ភាសន៍តាមខ្សែអាត់ជាមួយ ឌុច អតីតប្រធានសន្តិសុខខ្មែរក្រហម ស-២១ សម្ភាសន៍ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា សរសេរជាភាសាខ្មែរ និងអង់គ្លេស នៅថ្ងៃទី១៨ មិថុនា ឆ្នាំ១៩៩៩ UNHCHR Suspect Statement of KANG Keck Iev alias DUCH UNHCHR Suspect Statement of KANG Keck Iev alias DUCH | P | 00160890 | 00002507 | 00160922 |
| E3/106 | D86/23 | 00177620-00177630 00177631-00177640 00177641-00177651 | [លិខិតបញ្ជាក់ការជំនួសឯកសារ] កំណត់ហេតុនៃការសួរចម្លើយ ឌុច ចុះថ្ងៃទី ០១ ០៤ ២០០៨ [Surrogate Sheet] Written Record of Interview of Duch by CIJ on 01-04-2008 [Feuille remplacée] Procès verbal d'interrogatoire de Duch par CJI le 01-04-2008 | P | 00177625 | 00176535 | p. 5, 00177646 |
| E3/1560 | D288/6.52/4.25 | 00320786-00320789 00327325-00327327 00327328-00327331 | ឧបសម្ព័ន្ធ ២៥៖ កំណត់ហេតុសួរចម្លើយ ថ្ងៃទី៩ ខែមិថុនា ឆ្នាំ១៩៩៩ Annex 25: Written Record of Interview - 09 June 1999 Annexe 25: Procès-verbal d'interrogatoire - 09 juin 1999 | P | | | |
| E3/450 | D86/24 | 00178045-00178057 00178058-00178070 00195945-00195958 | កំណត់ហេតុនៃការសួរចម្លើយ ឌុច ចុះថ្ងៃទី ០២ ០៤ ២០០៨ Written Record of Interview of Duch by CIJ on 02-04-2008 Procès verbal d'interrogatoire de Duch par CJI le 02-04-2008 | P | 00178048 | 00178061 | 00195948 |
| E3/456 | D90 | 00198870-00198878 00198879-00198886 00198887-00198894 | កំណត់ហេតុនៃការសួរចម្លើយ ឌុច ចុះថ្ងៃទី ២៥ មិថុនា ២០០៨ Written Record of Interview of Duch by CIJ on 25-06-2008 Procès verbal d'interrogatoire de Duch par CJI le 25-06-2008 | P | 00198875 | 00198883 | 00198891 |
| E3/530 | D288/6.52/4.43 | 00095688-00095691 00329133-00329135 00327363-00327365 | ឧបសម្ព័ន្ធ ៤៣៖ កំណត់ហេតុសួរចម្លើយ ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០០២ Annex 43: Written Record of Interview - 4 July 2002 Annexe 43: Procès-verbal d'interrogatoire - 4 juillet 2002 | P | 00095691 | 00329135 | 00327365 |

00803427



| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/60 | D88 | 00195590-00195598 00195599-00195607 00195608-00195617 | [លិខិតបញ្ជាក់ការជំនួសឯកសារ] កំណត់ហេតុនៃការសួរចម្លើយ ឌុច ចុះថ្ងៃទី ០៣ មិថុនា ២០០៨ [Surrogate Sheet] Written Record of Interview of Duch by CIJ on 03-06-2008 [Feuille remplacée] Procès verbal d'interrogatoire de Duch par CJI le 03-06-2008 | P | 00195598 | 00195606 | 00195616 |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឲ្យជនជាប់ចោទ អៀង សារី (ម៉ោង ១០.៣៧) និង នួន ជា (ម៉ោង ១២.០៧) ចូលរួមដំណើរការសវនាការពីបន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការ និងបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់រង់ចាំ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទទាំងពីរមានភ្ជាប់មកជាមួយនិងកំណត់ហេតុនេះ) ។
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំ សាក្សី កាំង ហ្គេកអ៊ាវ ហៅឌុច ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោង០៩ ព្រឹក ថ្ងៃពុធ ទី ១៨ ខែ មេសា ឆ្នាំ ២០១២។

**កាលបរិច្ឆេទបន្តសវនាការ៖**

សវនាការនឹងបន្តនៅថ្ងៃពុធ ទី ១៨ ខែ មេសា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១២

ក្រឡាបញ្ជី | ក្រឡាបញ្ជី

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E.C.C.C. C.E.T.C.

សែ គុលឧត្តម | Roger PHILLIPS